**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

**តុលាការរដ្ឋប្បវេណី**
សំណុំរឿងលេខ:២១៤
ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០
សាលក្រមលេខ: ៥០ យ
ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង
## បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

**ដើមចោទ**

-ឈ្មោះ [redacted] ស្រីម៉ាច ភេទស្រី អាយុ ២៦ឆ្នាំ។ ប្ដីឈ្មោះ [redacted] ភ័ន់ឌី មានកូន០២នាក់។

-មានអាសយដ្ឋាននៅភូមិ[redacted]។

**អ្នកតំណាងដោយអាណត្តិ**

លោមមេធាវី [redacted] អត្តលេខ ២៤០ និងលោកស្រី [redacted] អត្តលេខ ២០០៣T។

**ចុងចម្លើយ**

-ឈ្មោះ [redacted] ភ័ន់ឌី ភេទប្រុស អាយុ ៣០ឆ្នាំ។ ប្រពន្ធឈ្មោះ [redacted] ស្រីម៉ាច មានកូន០២នាក់។

-មានអាសយដ្ឋាននៅ[redacted]។

## អង្គហេតុ និងចំណុចវិវាទ

### ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១-សុំឈប់រស់នៅជាអនីតិសង្វាសពីឈ្មោះ [redacted] ភ័ន់ឌី ។

២-សុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូន០២ នាក់។

៣-សុំសិទ្ធិបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែក។

### ខ-ដំណើររឿងក្ដី និងចំណុចវិវាទ

#### ខ.១-ការសង្ខេបអំពីរឿងក្ដី

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ដើមចោទ បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយ ត្រឹមត្រូវតាមប្រពៃណី តែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ឡើយ។ ក្រោយពីបានរួមរស់ជាប្ដីប្រពន្ធនឹងគ្នា មានកូន០២នាក់ គឺឈ្មោះ [redacted] ភ៉ាឌីន ភេទប្រុស កើតថ្ងៃទី២០ ខែមករា ឆ្នាំ ២០១៥ និងឈ្មោះ [redacted] ភ៉ាវីន ភេទប្រុស កើតថ្ងៃ២០ ខែឧសភា ឆ្នាំ ២០១៧។ ហើយនៅក្នុងអំឡុងពេលរួមរស់ជាប្ដីប្រពន្ធយើងមានទ្រព្យសម្បត្តិដោយឡែកមានដីទំហំ ១៥១ម² ដែលស្ថិតនៅភូមិក្ដីត្នោត ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦១១០១-០១៣១ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២០។ នៅក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាតែងតែមានភាពរកាំរកូសនឹងមិនចុះសម្រុងជាមួយគ្នា។



Scanned with CamScanner

**ខ.២-អង្គហេតុដែលគ្មានវិវាទ**

ខ.២.១-ដើមចោទឈ្មោះ [redacted] ស្រីម៉ាច បានរៀបការជាមួយចុងចម្លើយឈ្មោះ [redacted] វ៉ាន់ឌី កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ។

ខ.២.២-ដើមចោទឈ្មោះ [redacted] ស្រីម៉ាច ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] វ៉ាន់ឌី ដោយសារការរស់នៅជាប្តីប្រពន្ធមានភាពមិនចុះសម្រុងនឹងគ្នា ដោយចុងចម្លើយមានការប្រើប្រាស់គ្រឿងញៀននិង លេងល្បែងស៊ីសង បណ្តាលឲ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត។ រីឯ ចុងចម្លើយឈ្មោះ [redacted] វ៉ាន់ឌី ក៏បានទទួលស្គាល់ចំពោះមូលហេតុទាំងនេះដែរ។

ខ.២.៣-គូភាគីបានថ្លែងការណ៍ថាៈ ការរស់នៅជាប្តីប្រពន្ធបានបង្កើតកូន០២នាក់ គឺឈ្មោះ [redacted] វ៉ាឌីន ភេទប្រុស កើតថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ និងឈ្មោះ [redacted] វ៉ាវីន ភេទប្រុស កើតថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។ ផ្តល់សិទ្ធិអំណាចមេបាលើកូន០២នាក់ទៅឲ្យប្រពន្ធឈ្មោះ [redacted] ស្រីម៉ាច ។

ខ.២.៤-គូភាគីបានថ្លែងការណ៍ថាៈ ទ្រព្យរួម ទ្រព្យដោយឡែក គឺមាន ដោយបានឯកភាពគ្នាបែងចែករួចរាល់ហើយ។ ចំពោះ បំណុល គឺគ្មានទេ។

**ខ.៣-ចំណុចវិវាទ**

**ខ.៣.១ការលែងលះ**

តើដើមចោទមានមូលហេតុត្រឹមត្រូវតាមច្បាប់ ដើម្បីប្តឹងសុំលែងលះពីចុងចម្លើយដែរឬទេ?

**ខ.៣.២ ការកំណត់អ្នកមានសិទ្ធិអំណាចមេបា**

តើភាគីណាមានលក្ខណៈសម្បត្តិក្នុងការគ្រប់គ្រងកូន ឲ្យមានអនាគតល្អ?

**ខ.៣.៣ ទ្រព្យសម្បត្តិ**

តើភាគីទាំងពីរមានទ្រព្យសម្បត្តិរួម ឬទ្រព្យដោយឡែក ដែរឬទេ?

**ខ.៤-ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ**

**ការអះអាងរបស់ដើមចោទ**

ខ្លួនឈ្មោះ [redacted] ស្រីម៉ាច ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] វ៉ាន់ឌី ដោយសារការរស់នៅជាប្តីប្រពន្ធមានភាពមិនចុះសម្រុងនឹងគ្នា ដោយចុងចម្លើយមានការប្រើប្រាស់គ្រឿងញៀននិង លេងល្បែងស៊ីសង ដែលនាំឲ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត។ ខ្លួនមានការអនុគ្រោះ ដល់ចុងចម្លើយច្រើនដងមកហើយ ប៉ុន្តែនៅតែមិនមានការកែប្រែនោះឡើយ។ ចំពោះសិទ្ធិអំណាចមេបាលើកូន ខ្លួនសុំសិទ្ធិអំណាចមេលើកូនទាំង០២នាក់ រីឯទ្រព្យសម្បត្តិដោយឡែកខ្លួនប្រគល់ឲ្យទៅចុងចម្លើយ។

**ការអះអាងរបស់ចុងចម្លើយ**

ខ្លួនឯកភាពចំពោះការសុំឈប់រស់នៅជាអនីតិសង្វាសរបស់ដើមចោទ។ ខ្លួនសុខចិត្តប្រគល់កូនចំនួន ០២នាក់ឈ្មោះ [redacted] វ៉ាឌីន និងឈ្មោះ [redacted] វ៉ាវីន ឲ្យទៅដើមចោទ ហើយព្រមទទួលយកទ្រព្យសម្បត្តិដែលមានដីទំហំ ១៥១ម$^2$ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦១១០១-០១៣១ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២០។

## សំអាងហេតុ

**ក-ស្តីពីចំណុចវិវាទទី១**

តាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ ថាការរស់នៅជាប្តីប្រពន្ធមានភាពមិនចុះសម្រុងនឹងគ្នា ដោយប្តីបានប្រើប្រាស់គ្រឿងញៀន និងលេងល្បែងស៊ីសង បណ្តាលឲ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត។ រីឯ ចុងចម្លើយ ក៏បានទទួលស្គាល់ការអះអាងពីមូល



Scanned with CamScanner

ហេតុនៃការលែងលះរបស់ដើមចោទដែរ។ ផ្ទុយទៅវិញ ដើមចោទ និងចុងចម្លើយបានរៀបការ និងរួមរស់ជាមួយគ្នាជាប្តីប្រពន្ធជាយូរណាស់មកហើយ កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១៤ ដោយមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ស្របតាមមាត្រា៩៥៥ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

ដូច្នេះ តុលាការទទួលស្គាល់ថា ការរួមរស់ និងការរៀបអាពាហ៍ពិពាហ៍កន្លងមក គឺធ្វើឡើងតាមទំនៀមទម្លាប់ប្រពៃណី ហេតុនេះ គប្បី តុលាការសម្រេចផ្តាច់ចំណងអនីតិសង្វាសរវាងដើមចោទ និងចុងចម្លើយ បើទោះជាដើមចោទ និងចុងចម្លើយ ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ។

**ខ-ស្តីពីចំណុចវិវាទទី២**

ខ.១. ផ្អែកតាមសេចក្តីចម្លងសំបុត្រកំណើតលេខ០៤២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានក្រុងកំពង់ឆ្នាំង និង សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ០៨៩ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ផ្សារឆ្នាំង គឺបញ្ជាក់បានថាដើមចោទឈ្មោះ [redacted] **ស្រីម៉ាច** និងចុងចម្លើយឈ្មោះ [redacted] **វ៉ាន់ឌី** ពិតជាមានកូន ០២នាក់ កូនទី១ ឈ្មោះ [redacted] **វ៉ាឌីន** ភេទប្រុស កើតថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ និងកូនទី២ ឈ្មោះ [redacted] **វ៉ាវីន** ភេទប្រុស កើតថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៧ ប្រាកដមែន ។

ខ.២. ពិនិត្យឃើញថា កូនទី១ ឈ្មោះ [redacted] **វ៉ាឌីន** មានអាយុ ០៥ឆ្នាំ និងកូនទី២ ឈ្មោះ [redacted] **វ៉ាវីន** មានអាយុ ០៣ឆ្នាំ ដែលចាំបាច់ណាស់ ត្រូវមានការថ្នាក់ថ្នមពីម្តាយ ហើយដើមចោទក៏បានចិញ្ចឹមបីបាច់ថែរក្សាកូនរហូតមកដល់បច្ចុប្បន្ន។ ស្ថានភាពរបស់ដើមចោទក៏មានការងារធ្វើ ដែលមានពេលវេលាច្បាស់លាស់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនបាន ។ ដូច្នេះគប្បីតុលាការពិចារណាសម្រេច ដោយផ្អែកលើឧត្តមប្រយោជន៍របស់ក្មេង ដែលត្រូវការម្តាយគ្រប់គ្រង និងចិញ្ចឹមបីបាច់ថែរក្សាជាចាំបាច់ឲ្យមានអនាគតល្អបាន យោងតាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

**គ.ស្តីពីចំណុចវិវាទទី៣**

តាមការពិនិត្យមើលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦១១០១-០១៣១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ ២០២០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ឆ្នាំង ឃើញថា ទ្រព្យសម្បត្តិនេះពិតជាទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធឈ្មោះ [redacted] **ស្រីម៉ាច** ពិតប្រាកដមែន ហើយដើមចោទ ព្រមប្រគល់ទ្រព្យសម្បត្តិដោយឡែកនេះទៅឲ្យចុងចម្លើយ ដូច្នេះគប្បីតុលាការទទួលស្គាល់តាមការព្រមព្រៀងរបស់គូភាគី។

**ឃ-ការវិនិច្ឆ័យអំពីការទាមទារ**

-ការប្តឹងសុំលែងលះរបស់ដើមចោទ គប្បីតុលាការទទួលស្គាល់ថា បានធ្វើឡើងតាមទំនៀមទម្លាប់ និងប្រពៃណី ហេតុនេះ គប្បីតុលាការពិចារណាសម្រេចឲ្យដើមចោទ និង ចុងចម្លើយ បញ្ឈប់ការរស់នៅបែបអនីតិសង្វាសនេះចាប់ពីពេលនេះតទៅ។

-តុលាការទទួលស្គាល់លើការប្តឹងទាមទាររបស់ដើមចោទឈ្មោះ [redacted] **ស្រីម៉ាច** ចំពោះការសុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូន។ គប្បីតុលាការសម្រេចកំណត់យកឈ្មោះ [redacted] **ស្រីម៉ាច** ជាអ្នកមានអំណាចមេបាលើកូនទី១ឈ្មោះ [redacted] **វ៉ាឌីន** និងកូនទី២ឈ្មោះ [redacted] **វ៉ាវីន**។

-បន្ទាប់ពីបានពិនិត្យមើលភស្តុតាងដែលដើមចោទ និងចុងចម្លើយដាក់ជូនតុលាការ តុលាការពិនិត្យឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ អាចឲ្យតុលាការពិចារណាសម្រេចតាមច្បាប់។



Scanned with CamScanner

## ខ. ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្តតាមបញ្ញត្តិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្ដីសម្រេចបញ្ចប់

១-ផ្ដាច់ចំណងអនីតិសង្វាសរវាងដើមចោទឈ្មោះ [redacted] ស្រីម៉ាច និងចុងចម្លើយឈ្មោះ [redacted] **វ៉ានឌី** ចាប់ពីពេលនេះតទៅ។

២-កំណត់យកឈ្មោះ [redacted] **ស្រីម៉ាច** ជាអ្នកមានអំណាចមេបាលើកូនទី១ ឈ្មោះ [redacted] **វ៉ាឌីន** ភេទប្រុស កើតថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ និងកូនទី២ ឈ្មោះ [redacted] **វ៉ាវីន** ភេទប្រុស កើត២០ ខែឧសភា ឆ្នាំ២០១៧។

-ចុងចម្លើយដែលពុំមានអំណាចមេបាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។ រីឯ ដើមចោទដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ដើមចោទឲ្យស្របតាមមាត្រា១០៤០ ក្រមរដ្ឋប្បវេណី។

៣. ប្រគល់ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦១១០១-០១៣១ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២០ ស្ថិតនៅភូមិក្ដីត្នោត ឃុំស្រែថ្មី ស្រុក រលាប្អៀរ ខេត្តកំពង់ឆ្នាំង ឱ្យទៅចុងចម្លើយឈ្មោះ [redacted] វ៉ាន់ឌី។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុកចុងចម្លើយ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល០១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ក្រឡាបញ្ជី
ហត្ថលេខា និងត្រា: [redacted]

ចៅក្រម
ហត្ថលេខា និងត្រា: [redacted]

---

**បានឃើញ**
**ចៅក្រម**

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កំពង់ឆ្នាំង, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner